លេខ ៤១ ចេញផ្សាយថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែវិច្ឆិកា ឆ្នាំ២០២៤

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## មាតិកា


- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២០ — ទំព័រទី១
- សិក្ខាសាលាស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ញាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ.ស.២០២៤-២០២៨" — ទំព័រទី២
- កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ — ទំព័រទី២
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" — ទំព័រទី២
- កិច្ចប្រជុំស្តីពីការបំពេញកម្រងសំណួរនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទនិងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) — ទំព័រទី៣
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ — ទំព័រទី៣
- វេទិកាពិព័រណ៌បច្ចេកវិទ្យាហិរញ្ញវត្ថុប្រទេសសិង្ហបុរីប្រចាំឆ្នាំ២០២៤ (Singapore FinTech Festival 2024) នៅប្រទេសសិង្ហបុរី — ទំព័រទី៤
- កិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ — ទំព័រទី៤
- សិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ស្តីពី "25th APG Typology Workshop 2024" — ទំព័រទី៤
- សន្និបាតបច្ចេកវិទ្យាហិរញ្ញវត្ថុឥណ្ឌូនេស៊ី លើកទី៦ គ.ស. ២០២៤ ក្រោមមូលបទ "ចំណុចរួមនៃបច្ចេកវិទ្យា៖ ការបង្កើតអនាគតនៃហិរញ្ញវត្ថុ និងលើសពីនេះ" — ទំព័រទី៥
- កិច្ចប្រជុំលើកទី២ លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច ២០២៥-២០២៨ — ទំព័រទី៥
- សន្និសីទជាតិស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា" — ទំព័រទី៥
- កម្មវិធី "វេទិកាខេមអេដ មូលបត្រ និងបរធនបាលកិច្ច" — ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យចំនួន ២ និងប្រកាសចំនួន ១ របស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — ទំព័រទី៦
- ពិធីចុះអនុស្សរណៈស្តីពី "ការពង្រឹងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង អំពីសេវាធានារ៉ាប់រងកម្ពុជា" — ទំព័រទី៦
- វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" — ទំព័រទី៧
- កម្មវិធី ទិវាប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព ២០២៤ — ទំព័រទី៧
- ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា — ទំព័រទី៧
- វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" — ទំព័រទី៨
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM) — ទំព័រទី៨
- ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា — ទំព័រទី៩
- ទស្សនកិច្ចសិក្សា និងប្រជុំពិភាក្សាការងារជាមួយសមាគមបរធនបាល និងក្រុមហ៊ុនបរធនបាល នៅទីក្រុងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន — ទំព័រទី៩
- ពិធីចុះអនុស្សរណៈស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថល" — ទំព័រទី១០
- កម្មវិធីវិបស្សរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ប.យ.) — ទំព័រទី១០


## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២០

នារសៀលថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាណត្តិទី១ លើកទី២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ. នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២០។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០២៤-២០២៨

នាថ្ងៃអង្គារ ៥កើត និងថ្ងៃពុធ ៦កើត ខែកត្តិក ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ដល់ថ្ងៃទី៦ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច អមដោយសហការី បានអញ្ជើញចូលរួម "សិក្ខាសាលាស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០២៤-២០២៨" ក្រោមអធិបតីភាពរបស់ **លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារបញ្ច្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ក.ប.) នៅសណ្ឋាគារ ស្ទឹងសង្កែ ខេត្តបាត់ដំបង។ សិក្ខាសាលានេះមានការចូលរួមពីតំណាងលោកជំទាវ លោក លោកស្រីថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី និងថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អភិបាលរងនិងខេត្តកំពង់ឆ្នាំង ព្រមទាំងតំណាងមកពីនិយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.** តំណាងពីមន្ទីរសេដ្ឋកិច្ច និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។



**រូបភាព៖** សិក្ខាសាលាស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០២៤-២០២៨"។

## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃអង្គារ ៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី៣ គ.ស.២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង, ស្ថាប័ន, អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា គ.ស.២០២៤, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយប្រធាន/ប្រធានស្តីទីនាយកដ្ឋាន និងសហការីនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដោយមានការចូលរួមពីតំណាងថ្នាក់ដឹកនាំសាស្ត្រាចារ្យ និងនិស្សិតដែលជាតំណាងពីសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈពាក់ព័ន្ធផ្នែកបច្ចេកវិទ្យាក្នុងរាជធានីភ្នំពេញ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីទិដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology) និងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច (FinTech's Regulatory Sandbox in the Trust Sector) ក៏ដូចជាគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យា

ហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" (Guideline on FinTech's Regulatory Sandbox in the Trust Sector) ដែលបានដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ កន្លងទៅ។



រូបភាព៖ សាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំស្តីពីការបំពេញកម្រងសំណួរនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាល (កសហវ)

នាព្រឹកថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយសហការី បានចូលរួមកិច្ចប្រជុំស្តីពីការបំពេញកម្រងសំណួរនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឯក ចន្ថា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **កសហវ** និងជាអនុប្រធាន **ក.វ.ម** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំស្តីពីការបំពេញកម្រងសំណួរនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

នាថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។ សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលធាតុចូលពីគ្រប់តួអង្គពាក់ព័ន្ធទាំងក្រសួង ស្ថាប័នសាធារណៈ ទាំងស្ថាប័នអន្តរជាតិសំខាន់ៗ និងវិស័យឯកជន សម្រាប់ការរៀបចំវិធានការគោលនយោបាយខាងលើនេះ។

កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់នេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ដែលជាតំណាងពីក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករក្រោមឱវាទ **អ.ស.ហ.**។



រូបភាព៖សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## វេទិកាពិព័រណ៌បច្ចេកវិទ្យាហិរញ្ញវត្ថុប្រទេសសិង្ហបុរី ប្រចាំឆ្នាំ២០២៤ (Singapore FinTech Festival 2024) នៅប្រទេសសិង្ហបុរី

នាថ្ងៃពុធ-សុក្រ ៦-៨កើត ខែកត្តិក ឆ្នាំរោងឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៦-៨ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក ចេស ចាន់ដេត** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ និង**លោកស្រី ស៊ិន សុមាល័យ** ប្រធានការិយាល័យ និង**លោក ធយ ច័ន្ទមករា** អនុប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច មានកិត្តិយសត្រូវបានចាត់ឱ្យចូលរួម "វេទិកាពិព័រណ៌បច្ចេកវិទ្យាហិរញ្ញវត្ថុប្រទេសសិង្ហបុរី ប្រចាំឆ្នាំ២០២៤ (Singapore FinTech Festival 2024)" នៅប្រទេសសិង្ហបុរី ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech), ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃការវិវត្តន៍ FinTech ជាសកល ក៏ដូចជាបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។




រូបភាព៖ "វេទិកាពិព័រណ៌បច្ចេកវិទ្យាហិរញ្ញវត្ថុប្រទេសសិង្ហបុរី ប្រចាំឆ្នាំ២០២៤ (Singapore FinTech Festival 2024)" នៅប្រទេសសិង្ហបុរី។

## កិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃចន្ទ ១១ កើតខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា គ.ស. ២០២៤ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃនិយ័តករបរធនបាលកិច្ចតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី៣ គ.ស.២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## សិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ស្តីពី "25th APG Typology Workshop 2024"

នៅថ្ងៃចន្ទ-ពុធ ១១-១៣កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១-១៣ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.), **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច បានចូលរួមសិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ ដែលសហការរៀបចំឡើងដោយ ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Group on Money Laundering- APG) និងធនាគារកណ្តាលនៃប្រទេសម៉ាឡេស៊ី (Bank Negara Malaysia) ស្តីពី "25th APG Typology Workshop 2024" នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ សិក្ខាសាលាគំរូនេះរៀបចំឡើងក្នុងគោលបំណងដើម្បីចែករំលែក ចំណេះដឹង និងបទពិសោធអំពីនិន្នាការសកលស្តីពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ពាក់ព័ន្ធនឹង (១) ការប្រើប្រាស់នីតិបុគ្គលក្នុងគោលដៅខុសច្បាប់ (Abuse of Legal Persons) និង (២) ការក្លែងបន្លំ ឬឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Cyber Enabled Fraud/Scams)។ សិក្ខាសាលានេះ មានការចូលរួមពីតំណាងស្ថាប័នហិរញ្ញវត្ថុរដ្ឋ/ឯកជននៃបណ្តាប្រទេសសមាជិករបស់ APG និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងប្រព័ន្ធហិរញ្ញវត្ថុនិងការប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖សិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ស្តីពី "25th APG Typology Workshop 2024"។

## សន្និបាតបច្ចេកវិទ្យាហិរញ្ញវត្ថុឥណ្ឌូនេស៊ី លើកទី៦ គ.ស. ២០២៤ ក្រោមមូលបទ "ចំណុចរួមនៃបច្ចេកវិទ្យា៖ ការបង្កើតអនាគតនៃហិរញ្ញវត្ថុ និងលើសពីនេះ"

នាថ្ងៃអង្គារ-ពុធ ១៣-១៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ និងថ្ងៃទី១៣ ខែវិច្ឆិកា គ.ស.២០២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមសន្និបាតបច្ចេកវិទ្យាហិរញ្ញវត្ថុឥណ្ឌូនេស៊ី លើកទី៦ គ.ស.២០២៤ ក្រោមមូលបទ "ចំណុចរួមនៃបច្ចេកវិទ្យា៖ ការបង្កើតអនាគតនៃហិរញ្ញវត្ថុ និងលើសពីនេះ"នៅទីក្រុងហ្សាកាតា នៃប្រទេសឥណ្ឌូនេស៊ី។ នាឱកាសនេះ **ឯកឧត្តម ណឺ សាគល** ក៏បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាស្តីពី "ការរុញច្រានបរិយាបន្នហិរញ្ញវត្ថុ៖ តួនាទីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការបង្កើតពលានុភាពដល់ប្រទេសមួយចំនួននៅអាស៊ីដែលទទួល បានសេវាហិរញ្ញវត្ថុតិចតួច" ផងដែរ។




រូបភាព៖សន្និបាតបច្ចេកវិទ្យាហិរញ្ញវត្ថុឥណ្ឌូនេស៊ី លើកទី៦ គ.ស. ២០២៤ ក្រោមមូលបទ "ចំណុចរួមនៃបច្ចេកវិទ្យា៖ ការបង្កើតអនាគតនៃហិរញ្ញវត្ថុ និងលើសពីនេះ"។

## កិច្ចប្រជុំលើកទី២ លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច ២០២៥-២០២៨

នាថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ., **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃ ន.ប.ធ. អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី២ របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច ២០២៥-២០២៨ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច។



រូបភាព៖កិច្ចប្រជុំលើកទី២ លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច ២០២៥-២០២៨ ។

## សន្និសីទជាតិស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា"

នាថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានដឹកនាំសហការីអញ្ជើញចូលរួមក្នុងសន្និសីទជាតិស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ស្ថិតនៅសណ្ឋាគារ សុខា ភ្នំពេញ។ វេទិកានេះមានគោលបំណងបង្ហាញអំពីសមិទ្ធផលសំខាន់ៗនៃកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការកសាង និងពង្រឹងប្រព័ន្ធគាំពារសង្គមកម្ពុជាដល់ភាគីពាក់ព័ន្ធ និងសាធារណជន។



រូបភាព៖សន្និសីទជាតិស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា" ។

## កម្មវិធី "វេទិកាខេមអេដ មូលបត្រ និងបរធនបាលកិច្ច"

នាព្រឹកថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី "វេទិកាខេមអេដ មូលបត្រ និងបរធនបាលកិច្ច" ដែលរៀបចំដោយវិទ្យាស្ថានខេមអេដ។ វេទិកានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិភាក្សា និងចែករំលែកអំពីបច្ចុប្បន្នភាពនៃទីផ្សារមូលបត្រ និងបរធនបាលកិច្ចនៅប្រទេសកម្ពុជា និងទស្សនវិស័យអភិវឌ្ឍន៍នៃទីផ្សារទាំងពីរ។ កម្មវិធីនេះមានការអញ្ជើញចូលរួមវាគ្មិនកិត្តិយសពី **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា, លោក Han En Chen នាយកប្រតិបត្តិ នៃក្រុមហ៊ុន ស្ត្រងហូល ត្រាសធី និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករបរធនបាលកិច្ច និងនិយ័តករមូល-បត្រកម្ពុជា ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យនៃវិទ្យាស្ថានខេមអេដ ប្រមាណ ១៥០ រូប។



រូបភាព៖កម្មវិធី "វេទិកាខេមអេដ មូលបត្រ និងបរធនបាលកិច្ច"។

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យចំនួន ២ និងប្រកាសចំនួន ១ របស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក ផែម លាបហេង** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យចំនួន ២ និងប្រកាសចំនួន ១ រួមមាន៖ ១. សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការប្តឹងនិងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ២.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និង ៣.សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមលទ្ធកម្ម ក្រោមការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក/លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង/ស្ថាប័ន ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធ Zoom។



រូបភាព៖កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យចំនួន ២ និងប្រកាសចំនួន ១ របស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ពិធីចុះអនុស្សរណៈស្តីពី "ការពង្រឹងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង អំពីសេវាធានារ៉ាប់រងកម្ពុជា"

នាព្រឹកថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. បានអញ្ជើញចូលរួម

ជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងក្លិបអ្នកកាសែតកម្ពុជាស្តីពី "ការពង្រឹងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង អំពីសេវាធានារ៉ាប់រងកម្ពុជា"។ នៅអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។



រូបភាព៖ពិធីចុះអនុស្សរណៈស្តីពី "ការពង្រឹងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង អំពីសេវាធានារ៉ាប់រងកម្ពុជា"។

## វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"

ចាប់ពីថ្ងៃពុធ ៥ រោច ដល់ថ្ងៃសុក្រ ៧ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹងថ្ងៃទី២០-២២ ខែវិច្ឆិកា គ.ស. ២០២៤ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1, **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះ-បណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារ រៀបចំវគ្គបណ្តុះ-បណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្តលើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" ខេត្តត្បូងឃ្មុំ កំពង់ចាម និងកំពង់ធំ។



រូបភាព៖វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងការលើក។

## កម្មវិធីទិវាប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព ២០២៤

នាព្រឹកថ្ងៃអាទិត្យ ៩រោចខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា គ.ស ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គ-នាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយសហការីបានអញ្ជើញចូលរួមកម្មវិធីទិវាប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព២០២៤ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង**ហិរញ្ញវត្ថុ** នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ។



រូបភាព៖កម្មវិធីទិវាប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព២០២៤។

## ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា

នាថ្ងៃច័ន្ទ ១០ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គ-នាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយសហការីបានអញ្ជើញទទួលជួបប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារនិងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជាជាមួយក្រុមហ៊ុន Moores Rowland (Cambodia) Co. Ltd. តំណាង

ដោយ**លោក** Thomas Lee, Practising Director, **លោក** Baudouin Coomans, Secretary General និង**លោក** Anthony Galliano, Group CEO of CIM Holdings នៅទីស្តីការ **ន.ប.ធ.**។



រូបភាព៖ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច និងធនាគារ អូរៀនថល ម.ក បានសហការគ្នារៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងDatuk Phan Ying Tong នាយកគ្រប់គ្រង និងជានាយកប្រតិបត្តិនៃធនាគារ អូរៀនថល ម.ក ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលរបស់ធនាគារ អូរៀនថល ម.ក។កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមអំពីយន្តការបរធនបាលកិច្ចអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅកម្ពុជា ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកមកពីធនាគារ អូរៀនថល ម.ក ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។



រូបភាព៖បណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM)

នាព្រឹកថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី** និងជាអនុប្រធានទី១ **នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** និងមានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។




រូបភាព៖ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM)។

## ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៣ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ជាមួយ **លោក** Ashley Ong ជានាយកប្រតិបត្តិ និង**លោកស្រី** Yvonne Lee នាយកគ្រប់គ្រងផ្នែកនីតិកម្មរបស់ក្រុមហ៊ុន Lion Trust (Singapore) Limited នៅទីស្តីការ **ន.ប.ធ.**។



រូបភាព៖ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា។

## ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា

នាព្រឹកថ្ងៃសុក្រ ១៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ជាមួយ**លោក Kirumpalani Chelliah** ជាប្រធានគណៈកម្មាការវិនិយោគ និង**លោកស្រី អ:ស្មាត់ រ៉ូហ្សាន** អគ្គនាយិកាក្រុមហ៊ុនរបស់ក្រុមហ៊ុនអេទីកាជេនេរ៉លអ៊ិនស្ចូរេន (ខេមបូឌា)-ម.ក នៅទីស្តីការ **ន.ប.ធ.**។



រូបភាព៖ប្រជុំពិភាក្សាការងារអំពីស្ថានភាពទីផ្សារ និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា។

## ទស្សនកិច្ចសិក្សា និងប្រជុំពិភាក្សាការងារជាមួយសមាគមបរធនបាល និងក្រុមហ៊ុនបរធនបាល នៅទីក្រុងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

ចាប់ពីថ្ងៃព្រហស្បតិ៍ ដល់ថ្ងៃសុក្រ ១៣ និង១៤ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ និង ២៩ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.**, **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និង**លោក ណាង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងសហប្រតិបត្តិការ បានអញ្ជើញធ្វើទស្សនកិច្ចសិក្សា និងប្រជុំពិភាក្សាការងារជាមួយសមាគមបរធនបាល និងក្រុមហ៊ុនបរធនបាល នៅទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ដោយមានការសម្របសម្រួលពីក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក។ នៅក្នុងដំណើរទស្សនកិច្ចសិក្សារយៈពេលពីរថ្ងៃនេះ គណៈប្រតិភូនៃ **ន.ប.ធ.** បានជួបប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងបទពិសោធន៍អនុវត្តន៍ក្របខ័ណ្ឌបទប្បញ្ញត្តិ បរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសម្រាប់ការវិនិយោគ កិច្ចដំណើរការនៃសមាគមបរធនបាល សមាហរណកម្មបច្ចេកវិទ្យា ការអភិវឌ្ឍន៍ទីផ្សារ ការគ្រប់គ្រងហានិភ័យ លទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការ និងការអនុវត្តប្រកបដោយនិរន្តរភាព ក៏ដូចជាការចែករំលែកអំពីសក្តានុពល និងកាលានុវត្តភាពវិនិយោគក្នុងទីផ្សារបរធនបាលកិច្ចកម្ពុជាផងដែរ ជាមួយសមាគមបរធនបាលហុងកុង, ក្រុមហ៊ុន Morgan Stanley, ក្រុមហ៊ុន Forever Trust Limited និងក្រុមហ៊ុន Printrust Company (Singapore) Limited។ ដំណើរទស្សនកិច្ចខាងលើ ក៏មានថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ចូលរួមជាមួយផងដែរ ដើម្បីជំរុញការយល់ដឹងបន្ថែមអំពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចដល់ក្រុមការងាររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.។



រូបភាព៖ទស្សនកិច្ចសិក្សា និងប្រជុំពិភាក្សាការងារជាមួយសមាគមបរធនបាល និងក្រុមហ៊ុនបរធនបាល នៅទីក្រុងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីចុះអនុស្សរណៈស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថល"

នារសៀលថ្ងៃសុក្រ ១៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ណឹ សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថល" រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ពិធីចុះអនុស្សរណៈស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថល"។

## កម្មវិធីវិបស្សនា របស់ក្រុមការងារបញ្ញាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ប.យ.)

ចាប់ពីថ្ងៃព្រហស្បតិ៍ ដល់ថ្ងៃសៅរ៍ ១៣រោច-១៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ដល់ ៣០ ខែវិច្ឆិកា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោកស្រី វ៉ា ស៊ីម៉ែន** អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិកនៃនាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមកម្មវិធីវិបស្សនា របស់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ប.យ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសណ្ឋាគារ សង្គហៈមិត្ត ខេត្តកែប។ កម្មវិធីនេះមានការចូលរួមពីឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ លោក លោកស្រីអគ្គនាយក អគ្គនាយករង និងលោក លោកស្រីតំណាងមកពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង២៥ និងថ្នាក់ដឹកនាំមន្ត្រីរាជការនៅតាមបណ្តារអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។




រូបភាព៖កម្មវិធីវិបស្សនា របស់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ប.យ.)។